ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០៧

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

ក

ស

វ



Work Activities

ប្រចាំខែកក្កដា ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិនៃវិទ្យាសាស្ត្រនិងបច្ចេកទេស | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆមាសទី១ | ៨ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៦ |

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិ នៃវិទ្យាសាស្ត្រនិងបច្ចេកទេស

កាលពីថ្ងៃទី២១ ខែឧសភា និងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិនៃវិទ្យាសាស្ត្រនិងបច្ចេកទេស** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។



វិទ្យាសាស្ត្រ និងបច្ចេកទេសមានតួនាទីដ៏សំខាន់ ពិសេសក្នុងបរិការណ៍មួយដែលការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ត្រូវគិតគូរដល់ភាពប្រកួតប្រជែងដ៏ខ្លាំងនៅក្នុងសេដ្ឋកិច្ចសាកល និងភាពចាំបាច់នៃការប្រើប្រាស់សេដ្ឋកិច្ចពុទ្ធិសម្រាប់ការងារអភិវឌ្ឍ ដោយហេតុថាការជំរុញលើកកម្ពស់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងជួយដល់ការបង្កើនប្រសិទ្ធភាពការងារ ផលិតភាព តម្លៃបន្ថែម ដែលនឹងជួយអភិវឌ្ឍសេដ្ឋកិច្ចឲ្យផុតពីអន្ទាក់នៃភាពជាអ្នកមានចំណូលមធ្យមកម្រិតទាប និងលើកស្ទួយជីវភាពសង្គម និងគុណភាពនៃជីវិតរបស់ប្រជាជន។ ក្នុងគោលដៅជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ក្រសួងផែនការធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងសាធារណរដ្ឋកូរ៉េពីឆ្នាំ២០០៦ ហើយបានទទួលជំនួយបច្ចេកទេសឆ្នាំ២០១១-២០១៣ សម្រាប់អនុវត្តគម្រោង “ផែនការមេថ្នាក់ជាតិផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា២០១៤-២០២០ “។ ការអនុវត្តគម្រោងនេះត្រូវបានធ្វើឡើងដោយមានកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន សំដៅបង្កើតឲ្យមានក្របខណ្ឌគតិយុត្ត និងយន្តការស្ថាប័នសមស្របសម្រាប់ការជំរុញអនុវត្តគំនិតផ្តួចផ្តើមនេះ។ យ៉ាងណាក្តីក្នុងការអនុវត្ត ក៏ជាបទពិសោធពីបណ្តាប្រទេសនានា ដោយរួមទាំងបណ្តាប្រទេសនៃសហគមន៍អាស៊ានផង ការជំរុញការអភិវឌ្ឍ ការគ្រប់គ្រង និងការសម្របសម្រួលកិច្ចការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាមួយបណ្តាក្រសួង និងវិស័យឯកជន ក៏ដូចជាកិច្ចការជាមួយបរទេស ចាំបាច់ទាមទារឲ្យមានស្ថាប័នជាតិកម្រិតនយោបាយ



កំពូលមួយ ដើម្បីតំណាង គ្រប់គ្រង និងសម្រេចកិច្ចការនិងមាគ៌ាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានេះស្របតាមគោលនយោបាយរបស់ជាតិ និងតាមសំណើបច្ចេកទេស ដោយមានការសិក្សាច្បាស់លាស់ និងកំណត់បានត្រឹមត្រូវពីស្ថាប័នជំនាញ។ ក្នុងគោលដៅនេះ គេអាចសង្ខេបបានថា ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាទាមទារឲ្យមានយន្តការពីរជាចាំបាច់ ពោលគឺយន្តការសម្របសម្រួល និងជំរុញស្ថាប័នកណ្តាលមួយ និងយន្តការអនុវត្តនិងសហការប្រតិបត្តិការ នៃបណ្តាស្ថាប័នជំនាញ[១]។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិនៃវិទ្យាសាស្ត្រនិងបច្ចេកទេស។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃព្រហស្បតិ៍ ទី០៣ ខែកក្កដា ឆ្នាំ២០១៤ នៅវេលាម៉ោង ១៦:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយលើកទី២ បន្តពីការប្រជុំត្រួតពិនិត្យចុងក្រោយកាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសសកម្មពិសេសប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងសហការី ឯកឧត្តមរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម អគ្គលេខាធិការរាជរដ្ឋាភិបាល ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសហការី ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ព្រមទាំងសហការី ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ព្រមទាំងសហការី ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងសុខាភិបាល ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិកម្មសត្វ៖**



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់នូវខ្លឹមសារដែលមានសារៈសំខាន់បំផុតពាក់ព័ន្ធនឹងច្បាប់សុខភាពសត្វនិងផលិតកម្មសត្វ ដោយអធិប្បាយអំពីផលិតកម្មសត្វ តាំងពីដំណាក់កាលចិញ្ចឹមរហូតចេញជាផលិតផល ជាសាច់វេចខ្ចប់ ឬជាម្ហូបអាហារជាសាច់កំប៉ុងអំពីដំណាក់កាលកែច្នៃបឋម និងដំណាក់កាលកែច្នៃចុងក្រោយ ប្រមូលផ្តុំកម្រិតដែនសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ឯកឧត្តម រដ្ឋមន្ត្រី ឯកឧត្តមរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួងស្ថាប័នពាក់ព័ន្ធនានា ដែលបានចូលរួម បានលើកយោបល់ផុលផុសអស់រយៈពេលយ៉ាងយូរមក អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

- មាត្រា៨៖ តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្មឯកភាពទទួលយកខ្លឹមសារនៃមាត្រានេះ ប៉ុន្តែសំណូមពរឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពន្យល់ក្នុងសទ្ទានុក្រមនូវពាក្យ ផលិតកម្មកែច្នៃផលិតផលសត្វ ដែលមានខ្លឹមសារដូចការអធិប្បាយរបស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាមី បានលើកយោបល់ជូនអង្គប្រជុំ។

-មាត្រា៤១៖ តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ឯកភាពទទួលយកខ្លឹមសារនៃមាត្រានេះ ប៉ុន្តែសំណូមពរក្រសួងសាមីពន្យល់ឲ្យបានច្បាស់លាស់នៅក្នុងសទ្ទានុក្រមនូវពាក្យ ការផលិត ការលាយផ្សំ។

-មាត្រា៥៩៖ តំណាងក្រសួងពាណិជ្ជកម្ម ឯកភាពទទួលយកខ្លឹមសារនៃមាត្រានេះ ប៉ុន្តែសំណូមពរក្រសួងសាមី កែសម្រួលនិយមន័យពាក្យ ផលិតផលសត្វឡើងវិញ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានស្នើឲ្យក្រសួងពាណិជ្ជកម្មរៀបចំកែសម្រួលនិយមន័យក្នុងសទ្ទានុក្រមនៃពាក្យផលិតផលសត្វ ដើម្បីដាក់ជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលធ្វើការសម្របសម្រួលជាមួយក្រសួងសាមី។



-មាត្រា១២២៖ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាមី ស្នើសុំដកចេញ។

-មាត្រា១២៥៖ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាមី ស្នើសុំកែសម្រួលមាត្រានេះដោយយកគំរូតាមទម្លាប់ដែលសេចក្តីព្រាងច្បាប់មុនបានរៀបចំរួចហើយ។

សំណើររបស់ក្រសួងសាមី និងក្រសួងពាក់ព័ន្ធខាងលើអង្គប្រជុំឯកភាពទទួលយក។

ចំពោះការបន្ថែមថ្មី ឬការកែសម្រួលនិយមន័យនៃពាក្យថ្មីក្នុងសទ្ទានុក្រម ដែលតំណាងក្រសួងពាក់ព័ន្ធ និងក្រសួងសាមីបានលើកយោបល់ក្នុងកិច្ចប្រជុំនេះហើយដែលជាគន្លឹះឈានទៅដល់ការឯកភាពគ្នានោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានសម្រេចឲ្យរៀបចំសេចក្តីព្រាងនៃការពន្យល់ពាក្យថ្មីទាំងនោះផ្ញើជូន ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល ដើម្បីសរុបធ្វើសំយោគ ហើយឈានដល់ការឯកភាព ទាំងក្រសួងសាមី និងក្រសួងពាក់ព័ន្ធ។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង១៨:៤៥នាទី ក្រោមបរិយាកាសរីករាយ ស្និតស្នាល និងទទួលបានលទ្ធផលវិជ្ជមានតាមការរំពឹងទុក។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី៣០ ខែកក្កដា ឆ្នាំ២០១៤ នៅវេលាម៉ោង ៩:00 នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមី និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២-សេចក្តីព្រាងព្រះរាក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

៣- បញ្ហាផ្សេងៗ។

ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖



១-សេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក៖

ជាកិច្ចចាប់ផ្តើម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំបានលើកឡើងពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជាមានចំនួនច្រើនជាង១០ដងបើធៀបទៅនិងគ្រោះថ្នាក់ចរាចរណ៍នៅអឺរ៉ុប និងបានបញ្ជាក់ពីសារៈសំខាន់នៃច្បាប់ថ្មីជំនួសឲ្យច្បាប់ចាស់ដែលខ្វះខាត និងចំណុចសំខាន់ៗដែលថែមក្នុងច្បាប់ថ្មីជាអាទិ៍ ការពាក់មួកសុវត្ថិភាព ការកំណត់ល្បឿន ការត្រួតពិនិត្យគ្រឿងស្រវឹង ការដាក់ទោសប្បញ្ញត្តិការពារទប់ស្កាត់បទល្មើសមានការផ្តន្ទាទោសដាក់ពន្ធនាគារ និងការពិន័យរួមគ្នា។

ជាកិច្ចបន្ត **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** សុំឲ្យឯកឧត្តម **ត្រាំ អ៊ីវតិក** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ធ្វើសេចក្តីថ្លែងហេតុជូនអង្គប្រជុំ។

ឯកឧត្តមរដ្ឋមន្ត្រីបានលើកឡើងពីបញ្ហាសំខាន់ៗដែលធ្វើឲ្យមានការផ្លាស់ប្តូរថ្មីៗ៖

-ការអនុវត្តច្បាប់ចាស់ ស្តីពីចរាចរណ៍ផ្លូវគោក (៨/២/២០០៧) បានជួបប្រទះនូវការខ្វះខាតមួយចំនួនជាអាទិ៍ការមិនតម្រូវឲ្យអ្នករួមដំណើរតាមទោចក្រយានយន្តពាក់មួកសុវត្ថិភាព ការបើកបរលើសល្បឿនកំណត់ ការបើកបរស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង គឺជាចំណុចដែលត្រូវកែសម្រួល និងសមស្របទៅនឹងទសវត្សរ៍ សកម្មភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០១០ដល់២០២០ (Decade of Action for Road Safety) ដែលអង្គការសហប្រជាជាតិបានកំណត់ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនអន្តរជាតិនៅទីក្រុងម៉ូស្គូ ប្រទេសរុស្ស៊ី គឺកាត់បន្ថយចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ឲ្យបាន៥០%នៅបំណាច់ឆ្នាំ២០២០។

-ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍បច្ចុប្បន្នមាននិន្នាការកើនឡើង។ នៅឆ្នាំ២០១៣ មានជនរងគ្រោះសរុបចំនួន ១៦,២២៧ នាក់ ដែលក្នុងនោះស្លាប់ចំនួន ១៩៥០ នាក់ និងរបួសធ្ងន់ចំនួន ៥៦៧១ នាក់ គិតជាមធ្យមចំនួនអ្នកស្លាប់ជាង៥ នាក់ និងរបួសធ្ងន់១៦ នាក់ ក្នុងមួយថ្ងៃ។ គ្រោះថ្នាក់បង្កដោយម៉ូតូ មាន៧០% គ្រឿងស្រវឹង ១៣% ល្បឿន ៥០%។



-ការពាក់ខ្សែក្រវាត់សុវត្ថិភាពនៅក្នុងទីប្រជុំជន តម្រូវឲ្យអ្នកបើកបរនិងអ្នករួមដំណើរជិះកៅអីមុខនៃរថយន្តពាក់ខ្សែក្រវាត់សុវត្ថិភាព។ នៅក្រៅទីប្រជុំជន តម្រូវឲ្យអ្នកបើកបរនិងអ្នករួមដំណើរទាំងអស់តាមរថយន្តគ្រួសារ ពាក់ខ្សែក្រវាត់សុវត្ថិភាព។ សម្រាប់រថយន្តដែលមានចំណុះលើសពី៩នាក់ (រថយន្តដឹកជញ្ជូនអ្នកដំណើរធុនតូច និងរថយន្តដឹកជញ្ជូនអ្នកដំណើរធុនធំ) អ្នកអង្គុយក្រោយក៏ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាពដែរ ដោយត្រូវចាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាននៅទូទាំងប្រទេស។

-កន្លងមក ការសុំផ្លាកលេខសម្គាល់យានយន្តមានការយឺតយ៉ាវ ដូច្នេះហើយបានជាច្បាប់ថ្មី (មាត្រា៤៨) តម្រូវឲ្យគ្រប់ម្ចាស់ហាងលក់យានយន្តមានកាតព្វកិច្ចបំពេញបែបបទចុះបញ្ជីយានយន្ត សុំបណ្ណសម្គាល់យានយន្តនិងសុំផ្លាកលេខសម្គាល់យានយន្តឲ្យបានចប់សព្វគ្រប់មុននិងប្រគល់ឲ្យអ្នកទិញ។ ត្រង់ចំណុចនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថានៅ ស.រ.អា តម្រូវឲ្យមានបណ្ណបើកបរនិងការធានារ៉ាប់រងទៀតទើបទិញឡានបាន។

ជាកិច្ចពិភាក្សា ឯកឧត្តមប្រធានអង្គប្រជុំបានលើកយកមាត្រាមួយចំនួនជាអាទិ៍៖

-មាត្រា៥១ ដែលចែងថា "ម្ចាស់យានយន្តដែលតម្រូវឲ្យមានការធានារ៉ាប់រងជាកាតព្វកិច្ច ត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងស្របតាមច្បាប់ស្តីពីការធានារ៉ាប់រង និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការធានារ៉ាប់រងនៅពេលដែលយានយន្តត្រូវបានយកទៅធ្វើចរាចរណ៍នៅលើផ្លូវថ្នល់"។ ត្រង់មាត្រា៥១នេះ អង្គប្រជុំអន្តរក្រសួងបានរក្សាទុកតាមសំណូមពររបស់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសុំរក្សាគោលការណ៍នេះ និងមតិរបស់តំណាងក្រសួងសុខាភិបាល និងតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានលើក

ឡើងការរក្សាទុកមាត្រា៩១នេះជាការរំលេច ការបង្ហាញ ការពញ្ញាក់ ឲ្យឃើញមានច្បាប់ធានារ៉ាប់រងក្នុងច្បាប់ចរាចរណ៍ផ្លូវគោក ហើយក្នុងច្បាប់ចរាចរណ៍ផ្លូវគោកនានាក្នុងសកលលោក មានចែងពាក់ព័ន្ធនិងការធានារ៉ាប់រងនេះដល់ទៅមួយជំពូក មិនមែនមួយមាត្រាដូចច្បាប់ថ្មីនេះទេ។ ចំណែកតំណាងក្រុមប្រឹក្សាអ្នកច្បាប់ មានមតិថាគួរលុបចោលមាត្រា៩១នេះ និងគួរដាក់ឲ្យនៅក្នុងច្បាប់ធានារ៉ាប់រងវិញតាមគោលការណ៍ "គ្របណា ឆ្នាំងហ្នឹង" ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនេះ តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៅរក្សាការពារមតិរបស់ខ្លួនដដែល។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក្រោយពីបានសុំមតិរបស់តំណាងក្រសួងសេដ្ឋកិច្ច ដែលមានតែអ្នកជំនួសហើយមិនមានលទ្ធភាពឆ្លើយនោះ បានសម្រេចថាគួរដាក់មាត្រា៩១ ដើម្បីឲ្យអ្នកបើកបរយល់ដឹងខ្លះៗ។

-មាត្រា៨២ ដែលចែងថា "ជនណាប្រើប្រាស់យានជំនិះដោយគ្មានបណ្ណសម្គាល់យានជំនិះ ឬគ្មានផ្លាកលេខសម្គាល់យានជំនិះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ថ្ងៃទៅ១ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ រៀល ទៅ ៨០០ ០០០ រៀល" ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** យល់ឃើញថាមាត្រានេះធ្វើឲ្យប៉ះពាល់ដល់អ្នកប្រើប្រាស់ម៉ូតូចាស់ៗដែលមានចំនួនច្រើន ព្រោះថាពាក្យយានជំនិះរួមទាំងរថយន្តនិងម៉ូតូ។ ដូច្នេះគួរប្តូរពាក្យយានយន្តទៅជាពាក្យរថយន្តវិញ។ ចំណែកម៉ូតូ ត្រូវយកមាត្រា៧១ មកអនុវត្តវិញ។

-មាត្រា៧ ដែលចែងថា "ការបើកបរយានជំនិះគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ស្តាំជានិច្ច។ គ្រប់យានជំនិះដែលមានចលនានៅលើផ្លូវថ្នល់ត្រូវតែមានអ្នកបើកបរ" ត្រូវបន្ថែម "និងអ្នកបើកបរបម្រុង"។ សម្រាប់យានជំនិះប្រភេទណា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងពិភាក្សាជាមួយក្រុមហ៊ុន។

-មាត្រា៩២ ដែលចែងថា "គ្រប់យានដ្ឋានជួសជុលយានយន្តនិងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្នុងករណីចាំបាច់ត្រូវមានការត្រួតពិនិត្យពីក្រសួងមហាផ្ទៃ។ ការគ្រប់គ្រងយានដ្ឋានជួសជុលនិងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវ កំណត់ដោយអនុក្រឹត្យ"។

ក្នុងមាត្រានេះត្រូវបន្ថែម "ក្រសួងឧស្សាហកម្មនិងសិប្បកម្ម" មួយទៀតតាមសំណូមពររបស់ក្រសួងដែលមានភារកិច្ចគ្រប់គ្រងយានដ្ឋានកែច្នៃដំឡើងយានយន្ត។

២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា៖

អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងព្រះរាជក្រឹត្យនេះ។

៣- បញ្ហាផ្សេងៗ៖

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង១១:៤៥នាទី ក្រោមបរិយាកាសរីករាយ ស្និតស្នាល និងទទួលបានលទ្ធផលវិជ្ជមានតាមការរំពឹងទុក។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០១៤*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំឆមាសទី១ ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ដែលដឹកនាំដោយឯកឧត្តម **ឌុយ ធៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមសមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀបក្នុងឆមាសទី១ដូចគ្នា ឆ្នាំ២០១៤និងឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ៤,៧%។ អត្រាអតិផរណានេះ មានកម្រិតប្រហាក់ប្រហែលនឹងទិសដៅ៥% របស់រាជរដ្ឋាភិបាល។

តារាង១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១២ដល់ឆ្នាំ២០១៤

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា[P] | សីហា[P] | កញ្ញា[P] | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ខែដូចគ្នាឆ្នាំ | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | **៥,៣%** | **៥,២%** | **៥,១%** | | | | |
| ២០១៣ | ខែដូចគ្នាឆ្នាំ | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២ | ៤,១ | ៤,៧ | ៣,០% |
| ២០១២ | ខែដូចគ្នាឆ្នាំ | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |

P:តួលេខខែ កក្កដា សីហាកញ្ញា និងប្រចាំឆ្នាំ២០១៣ ជាតួលេខព្យាករណ៍(តាមវិធីសាស្រ្ត DECOMPOSITION)

តារាង១.២. សន្ទស្សន៍ថ្លៃ អតិផរណា និងអត្រារួមចំណែកក្នុងអតិផរណា (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០១៤ | អតិផរណា ឆមាសទី១ ឆ្នាំ២០១៤) | អត្រារួមចំណែក (%) |
|---|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១៥៧,៣% | ៤,៧% | ១០០% |
| ការសិក្សា | ១៥៩,៧% | ៨,៨% | ២% |
| ភោជនីយដ្ឋាន | ២១៨,៣% | ៨,២% | ១០% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | | |
|---|---|---|---|
| សុខាភិបាល | ១២៧,៣% | ៨,១% | ៩% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១៤០,៦% | ៧,៩% | ៥% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១៣៥,២% | ៥,៩% | ២% |
| ម្ហូបអាហារ | ១៨១,០% | ៥,៦% | ៥១% |
| សម្លៀកបំពាក់ និងស្បែកជើង | ១៣០,២% | ៤,០% | ៣% |
| ការកម្សាន្ត និងវប្បធម៌ | ១១១,៥% | ៤,៣% | ៣% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងឥន្ធនៈផ្សេងទៀត | ១៣១,៦% | ៣,៦% | ១៣% |
| ការដឹកជញ្ជូន<br>ក្នុងនោះ ប្រេងសាំង | ១២៩,៩%<br>១២៨,៤% | -០,៣%<br>-២,៦% | -១%<br>-៣% |
| ទូរគមនាគមន៍ | ៦៩,១% | -៣,០% | -១% |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៤៤,១% | -៥,០% | -២% |

*កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%*

- មុខទំនិញដែលមានការឡើងថ្លៃខ្ពស់គួរឲ្យកត់សម្គាល់មាន ផ្លែឈើ ១០,២% ឧស្ម័ន ៨,៣% សាច់ជ្រូក ៨,២% សាច់គោស្រស់ ៧,២% និងត្រីស្រស់៧% ។

➡**អត្រាប្តូរប្រាក់** : ជារួមអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយវត្ថុបរទេសមានស្ថេរភាព។

| ប្រភេទ | ចុងឆមាសទី១ ២០១៤ | ចុងឆមាសទី១ ២០១៣ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤០៤០៛ | ៤០៦២៛ | -០,៥% |
| **៛/១បាត** | ១២៤៛ | ១៣១៛ | -៥,៣% |
| **៛/១ដុង** | ០,១៩០៛ | ០,១៩៣៛ | -១,៦% |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០១៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ៥០០៤,៤ ពាន់លានរៀល ស្មើនឹង ៤៩% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះចំណូលចរន្តមានចំនួន ៤៩៦៥,៩ ពាន់លានរៀល ស្មើនឹង ៥៩% នៃផែនការ និងចំណូលមូលធនចំនួន ៣៨,៥ ពាន់លានរៀល។

➢ បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំមុន ចំណូលថវិកាជាតិកើនឡើង ១៧% ដែលក្នុងនោះចំណូលចរន្តកើនឡើង ២២% ។

➢ ក្នុងចំណូលចរន្ត : ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន ៤៤១០ ពាន់លានរៀល ស្មើនឹង ៥៣% នៃផែនការប្រចាំឆ្នាំ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៣ ចំណូលសារពើពន្ធកើនឡើង ២៣% ដែលក្នុងនោះ ពន្ធ និងអាករគយ កើនឡើង ៣០% និងចំណូលពន្ធដារកើនឡើង ១៣% ។

ក្រាហ្វ ២.១. សមាសធាតុចំណូលសារពើពន្ធ : ពន្ធនិងអាករគយ និងចំណូលពន្ធដារ តាមឆមាស (២០១២-២០១៤)

យោងតាមក្រាហ្វ យើងសង្កេតឃើញថាចំណូលពន្ធនិងអាករគយនៅតែមានកម្រិតខ្ពស់ជាងចំណូលពន្ធដារ ។




| | ឆមាស១ (២០១២) | ឆមាស២ (២០១២) | ឆមាស១ (២០១៣) | ឆមាស២ (២០១៣) | ឆមាស១ (២០១៤) |
|---|---|---|---|---|---|
| ចំណូលសារពើពន្ធ | 3126 | 3276 | 3599 | 3635 | 4410 |
| ចំណូលពន្ធ និងអាករគយ | 1815 | 1898 | 2006 | 2079 | 2598 |
| ចំណូលពន្ធដារ | 1555 | 1409 | 1891 | 1644 | 1818 |

**តារាង២.១. សមាសភាពនៃចំណូលចរន្ត**

| មុខចំណូល | អនុវត្តផែនការ | %Δ ធៀបនឹងឆ.១ឆ្នាំ២០១៣ | **មុខចំណូល** | អនុវត្តផែនការ | % Δធៀបនឹង ឆ.១ ឆ្នាំ២០១៣ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** | ៥៣% | +២២,៥% | **ចំណូលមិនមែនសារពើពន្ធ** | ៤០% | +២១,៩% |
| ✓ពន្ធនិងអាករគយ | ៥៦% | +២៩,៥% | ✓នេសាទ | ៦៦% | +៧៣,៨% |
| -ពន្ធគយ (របបនាំចូល) | — | +២១,៤% | ✓ រុក្ខាប្រមាញ់ | ៨៥% | +២០១,៥% |
| -អាករពិសេសលើរបបនាំចូល | — | +៣១,៣% | ✓សម្បទានរ៉ែ | ១៤% | +១២១,៦% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | — | +២៦,៦% | ✓អាកាសចរណ៍ស៊ីវិល | ៥៧% | +៥៣,១% |
| -អាករនាំចេញ | — | +១១០,០% | ✓ ផលទុនទេសចរណ៍ | ២៩% | +១,៦% |
| -អាករបន្ថែមលើផលិផលគេលសិលា | — | +៨,១% | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៧,៥% | –៨០,៩% |
| ✓ ចំណូលពន្ធដារ | ៥៤% | +១២,៧% | ✓អាករស្ថានទូត (លិខិតឆ្លងដែន និង | ៤០% | +២៩,៤% |
| -ពន្ធលើប្រាក់បៀវត្ស | ៥៤% | +២៣,៧% | ទិដ្ឋាការ) | ៤២% | +៥៤,៤% |
| - ពន្ធលើប្រាក់ចំណេញ | ៦៧% | +២១,២% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ៣៩% | +៣៦,៩% |
| - ពន្ធលើឈ្នួលផ្ទះ–ដី | ៦១% | +៣៣,៤% | ✓ ជួលសហគ្រាស សម្ភារៈ | ៨១% | –២៩,១% |
| - អាករលើផលរបរ | ៤២% | +៣,៨% | ✓លក់អចលនកម្ម (ទ្រព្យសម្បត្តិរដ្ឋ) | ៦០% | +៩៦% |
| - អាករលើតម្លៃបន្ថែម | ៤៦% | +៩,៧% | ✓ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | | |
| -អាករពិសេស | ៤៩% | +៥,៣% | | | |
| -ចំណូលផ្សេងៗ | ៨៧% | +៤៥,៩% | | | |
| -ថវិកាខេត្ត–រាជធានី | ៣៧% | –៩,១% | | | |
| ✓ ចំណូលសារពើពន្ធផ្សេងៗ | ៤១% | –២,៥% | | | |
| –កាស៊ីណូ | ៤៨% | –២,៧% | | | |
| –អាជ្ញាបណ្ណក្នុងស្រុក | ៦៤% | +៨៧,២% | | | |
| – កម្រៃគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៣៥% | –៩,៧% | | | |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ ឆ្នាំ២០១៤ អនុវត្តបានចំនួន ៣២៣៣ពាន់លានរៀល ស្មើនឹង ២៤% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន២៧២៩,៩ពាន់លានរៀល ស្មើនឹង៣៣% នៃផែនការ និងចំណាយមូលធនចំនួន ៥០៣,១ ពាន់លានរៀល ។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នា ឆ្នាំ២០១៣ ចំណាយថវិកាជាតិកើនឡើង៤% ក្នុងនោះ ចំណាយចរន្តកើនឡើង៥% និងចំណាយមូលធនកើនឡើង០,២% ។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០១៤ មានអតិរេកចំនួន ១៧៧១,៤ ពាន់លានរៀល ស្មើនឹង ៤៤៣ លានដុល្លារ ស.រ.អា។

## ៣)ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៤ មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ M2 មានចំនួន ៣៨៦១៤ ពាន់លានរៀល កើនឡើង ២២% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។

➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើននៃរូបិយវត្ថុក្រៅធនាគារ១២% ប្រាក់បញ្ញើចរន្ត ៣៩% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៣០% និងប្រាក់បញ្ញើជារូបិយបណ្ណ ២២%។

➢ចំនួនប្រាក់រៀលនៅក្នុង និងក្រៅធនាគារសរុប មានចំនួន១៧,០% នៃរូបិយវត្ថុ M2 រីឯប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,០%។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុកម្ពុជានាចុងឆមាសទី១ ឆ្នាំ២០១៤




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន៣៨៣៤លានដុល្លារ កើនឡើង១១%ធៀបនឹងឆមាសទី១ឆ្នាំ២០១៣ ។

➢**ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា** ជាទូទៅមានការកើនឡើង ដោយក្នុងឆមាសទី១ ឆ្នាំ២០១៤ មានចំនួន ១២២៩២ ពាន់លានរៀល កើនឡើង ២៦% បើធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០១៣។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ**មានចំនួន ៣៣០៦២ ពាន់លានរៀលកើនឡើង ១២% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣ ។

➢**ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**មានចំនួន ៦៥៦៨,៥ ពាន់លានរៀល កើនឡើង៤៧% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។

➢***អត្រាការប្រាក់ប្រចាំឆ្នាំ***

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០១៤ | ចុងឆមាសទី១ ឆ្នាំ២០១៣ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៨៣% | ៥,៩៨% | –៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,១២% | ១១,៩៣% | +៣៥% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៧% | ៤,៤៣% | –៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥% | ១១,៧១% | –២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ៣២,១% | ២៨,២% | +១៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅស្ថាបនា | ២៨,២% | ៣៣,០% | –១៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ២៥,៨% | ៣១,៨% | –១៩% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

ក្នុងឆមាសទី១ ឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

➡កសិកម្មៈ

➢ មកដល់ចុងឆមាសទី១ ឆ្នាំ២០១៤ ផ្ទៃដីដាំស្រូវនៅព្រះរាជាណាចក្រកម្ពុជាមានចំនួន ១៦៧៨,៣ពាន់ហិកតា ស្មើនឹង ៦៥% នៃផ្ទៃដីដាំស្រូវសរុបក្នុងឆ្នាំ២០១៣។ តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ ២០១២ ២០១៣ និង ៦ខែដើមឆ្នាំ២០១៤។

| ប្រភេទដំណាំ | ឆមាសទី១-២០១៤ | ឆ្នាំ២០១៣ | ឆ្នាំ២០១២ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ១៦៧៨,៣ | ២៥៦៨ | ២៥១២ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ៩២,១ | ១៨៣,០ | ១៨៤,៨ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៤៩១,៣ | ១៩៤,២ | ៣៣៨,៨ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ៣,១ | ៨,០ | ៤,៣ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ២៤,១ | ២៩,១ | ៣៩,៣ |
| ផ្ទៃដីដាំសណ្ដែកបាយ (ពាន់ហិកតា) | ៣៦,៣ | ៩៦,៥ | ៤៦,៤ |
| ផ្ទៃដីដាំសណ្ដែកដី (ពាន់ហិកតា) | ១៤,៧ | ១៥,៦ | ១៤,៧ |
| ផ្ទៃដីដាំសណ្ដែកសៀង (ពាន់ហិកតា) | ៤១,៣ | ១០៣,៤ | ៥៨,២ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា)<br>ក្នុងនោះ ផ្ទៃដីចៀរជ័រ | ៣២៧,៦<br>៨៨,៥ | ៣២៨,៨<br>៧៨,៥ | ២៨០,១<br>៥៥,៤ |

➢ ផលិតផលនេសាទមានចំនួន **៣៤៩,០ ពាន់តោន** កើនឡើង ១១%បើធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ២០១៣។

➡ឧស្សាហកម្មៈ

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២១៣៩,៧ GWh កើនឡើង ១៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ៣៣៨,១ GWh កើនឡើង ១៧៦%។

➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២៧១៤,០លានដុល្លារ កើនឡើង ១២% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្មៈ

| ប្រភេទ | ចំនួនៈ ឆមាសទី១ ឆ្នាំ២០១៤ | ចំនួនៈ ឆមាសទី១ ឆ្នាំ២០១៣ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ៩៥ | ៨៨ | +៨% |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១២១៤ | ៩៩៦ | +២២% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៣១ | ១១៤ | +១៥% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | — | ៥៩ | — |

➡**សំណង់**ៈ

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤២៧២,៧ពាន់ម$^2$ ថយចុះ១២% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ១៧៧៤,៥លានដុល្លារ ថយចុះ៨% បើធៀបនឹង៦ខែដើមឆ្នាំ២០១៣។ ក្នុងនោះៈ ប្រភេទសំណង់សំខាន់ៗមានៈ

ប្រភេទសំណង់សំខាន់ៗមាន :

| *ប្រភេទសំណង់* | ពាន់ម៉ $^{២}$ :ឆមាសទី១ ឆ្នាំ២០១៤ | ពាន់ម៉ $^{២}$ :ឆមាសទី១ ឆ្នាំ២០១៣ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ១៩៧៣,៦ | ៨៨៧,៥ | +១២២% |
| ឧស្សាហកម្ម | ១០៧៩,៤ | ៤២៦,២ | +១៥៣% |
| ពាណិជ្ជកម្ម | ៨៤៧,៦ | ៣១៣៥ | -៧៣% |
| ទេសចរណ៍ | ១៦៤,៥ | ១៤៧,៥ | +១១% |
| ... | | | |
| អនុញ្ញាតសរុប | ៤២៧២,៧ | ៤៨៧១,៦ | -១២% |

➢ **ដូច្នេះ**ក្នុងការអនុញ្ញាតឆមាសទី១ ឆ្នាំនេះ សំណង់ដែលពេញនិយមគឺលំនៅឋាន (៤៦% នៃផ្ទៃក្រឡាសរុប) និងឧស្សាហកម្ម (២៥% នៃផ្ទៃក្រឡាសរុប)។

➡ **ការងារ:**

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៤ (នាក់) | ឆមាសទី១ ឆ្នាំ២០១៣ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកទទួលបានការធ្វើតាមរយៈក្រសួងនិងក្រុមហ៊ុន | ២៤៣៣៣ | ១៥៣៦៩ | +៥៨% |
| អ្នកទទួលបានការធ្វើក្នុងប្រទេស | ១៧៥១៣ | ៧៨៨៩ | +១២២% |
| អ្នកទទួលបានការធ្វើក្រៅប្រទេស | ៦៨៣០ | ៧៤៨០ | –៩% |

➡ **វិនិយោគ:**

➢គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មី និងពង្រីក) មានចំនួន ១៣០ គម្រោង (ឆមាសទី១ ឆ្នាំ២០១៣ មានចំនួន ៧៣ គម្រោង)។ ជាទុនវិនិយោគ ការអនុញ្ញាតមានទឹកប្រាក់ចំនួន ២៩៤១,៩លានដុល្លារ កើនឡើង២៤% បើធៀបនឹងឆមាសទី១ ឆ្នាំ ២០១៣។ គម្រោងទាំងនេះអាចបង្កើតការងារបាន ១៤៤,៥ ពាន់នាក់។

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៤ | ឆមាសទី១ ឆ្នាំ២០១៣ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ២៩៤១,៩ | ២៣៦៧,០ | +២៤% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៩១,១ | ៧៦,៤ | +១៩% |
| វិស័យឧស្សាហកម្ម | ២៥១៨,៤ | ៣៩៣,១ | +៥៤១% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ២០០៨,០ | ២២,២ | +៨៩៤៥% |
| វិស័យទេសចរណ៍ | ១៧៨,៧ | ១០៦,០ | +៦៩% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៥៣,៧ | ១៧៩១,២ | –៩១% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ១៣០ | ៧៣ | +៧៨% |
| **បង្កើតការងារ (ពាន់នាក់)** | ១៤៤,៥ | ១១១ | +៣០% |

➡ **សេវាកម្ម និងទេសចរណ៍:**

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី :

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ២០១៤ | *ចំនួន* :ឆមាស១ ឆ្នាំ២០១៣ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២០២៤ | ១៣៦៨ | +៤៨% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២២ | ៦ | +២៦៧% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | — | ៨១៤ | — |

➢**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប៥កំពង់ផែ) មានចំនួន ៦៦៤៤,៥ ពាន់តោន កើនឡើង៩៧,៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។ ក្នុងនោះ:

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៤ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០១៣(ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ៩៥០,៨ | ៨២៦,០ | +១៥% |
| កំពង់ផែកំពង់សោម | ៤១៩២,៩ | ១៥២២,១ | +១៧៥% |
| កំពង់ផែស្រែអំបិល និងកោះកុង | ៨៧៣,៥ | ៣៩៩,៥ | +១១៩% |
| កំពង់ផែឧកញ៉ាម៉ុង | ៦២០,៩ | ៣៣៨,៣ | +៨៤% |

**អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៤ (ពាន់នាក់) | ឆមាសទី១ ឆ្នាំ២០១៣(ពាន់នាក់) | បម្រែបម្រួល |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៧១,៩ | ៥៤,០ | +១២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៣៣,៧ | ១០៣,២ | +៣០% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៥៩៦,៩ | ២៣២៨,៤ | +១២% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៤៥៤,៨ | ៤៤១,៣ | +៣% |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ២១៨៨,៧ | ២០៩២,៦ | +៥% |
| ✓តាមផ្លូវអាកាស | ១១២៦,០ | ១០០៩,២ | +១២% |
| ✓ តាមផ្លូវគោក និងទឹក | ១០៦២,៧ | ១០៨៣,៤ | –២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆមាសទី១ ឆ្នាំ២០១៤ មានចំនួន ១៩១៧៤,២ ពាន់លានរៀលកើនឡើង ៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣។ ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន:

| បរិយាយ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៣ | បរិយាយ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៣ |
|---|---|---|---|
| ប្រេងសាំង<br>ប្រេងម៉ាស៊ូត | +៣%<br>+៦% | ត្រាក់ទ័រនិងគោយន្ត(ជាគ្រឿង)<br>ម៉ូតូ(ជាគ្រឿង) | +២០%<br>+២៣% |
| ឧស្ម័ន | -១៦% | អង្ករ | -៧៥% |
| អគ្គិសនីនាំចូល | -៦% | ផ្លែឈើនិងបន្លែ | +១៥០% |
| ដែកសំណង់ | +២៦% | ជីនិងថ្នាំកសិកម្ម | +៣៦% |
| ស៊ីម៉ង់ត៍ | +៤០% | បារី | +២២៣% |
| គ្រឿងអេឡិចត្រូនិក | +១៥១% | ភេសជ្ជៈ | +១១៧% |
| រថយន្តសរុប (ជា ព.ល.រ)<br>រថយន្តសរុប (ជាគ្រឿង) | +១២%<br>+៤% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១០% |

➡**ការនាំចេញ** ក្នុងឆមាសទី១ ឆ្នាំ២០១៤ មានចំនួន ១៥៤៣៥ពាន់លានរៀល កើនឡើង ២១% ធៀបនឹងឆមាសទី១ ឆ្នាំ ២០១៣។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន:

| *ទំនិញ* | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៣ | *ទំនិញ* | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៣ |
|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +២៧២% | ផលិតផលនេសាទ | +១% |
| វាយនភណ្ឌនិងស្បែកជើង | +១៤% | កៅស៊ូ | +៤០% |
| អង្ករ | 0 | | |

➡ក្នុងឆមាសទី១ ឆ្នាំ២០១៤ ជញ្ជីងពាណិជ្ជកម្ម មានឱនភាព ៣៧៣៩ ពាន់លានរៀល ស្មើនឹង ៩៣៥លានដុល្លារ ស.រ.អា ។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆមាសទី១ ឆ្នាំ២០១៤ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោមៈ

| ល.រ. | សូចនាករ | % Δ ធៀបនឹងឆមាស១ ឆ្នាំ២០១៣ | កំណត់សម្គាល់ |
|---|---|---|---|
| ១ | ថ្លៃផ្លែឈើ | +១០,២% | — |
| ២ | ថ្លៃក្រុមការសិក្សា | +៨,៨% | — |
| ៣ | ថ្លៃក្រុមសុខាភិបាល | +៨,១% | — |
| ៤ | កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | -១០% | ស្ថិតក្នុងចំណូលសារពើពន្ធផ្សេងៗ |
| ៥ | ក្រុមហ៊ុនចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម | +៤៨% | — |
| ៦ | ទំនិញដឹកជញ្ជូនតាមផែសរុប | +១១៥% | — |
| ៧ | ការនាំចូលផ្លែឈើ និងបន្លែ | +១៥០% | — |
| ៨ | ការនាំចូលបារី | +២២៣% | — |
| ៩ | ការនាំចេញអង្ករ | 0 | — |

## ៧) ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោមៈ*

១) ទោះបីជាការកើនឡើងនៃថ្លៃទំនិញប្រើប្រាស់ក្នុង៦ខែដើមឆ្នាំឆ្នាំ២០១៤ មានកម្រិតខ្ពស់ជាងកាលពីឆ្នាំ២០១៣ក៏ដោយ ក៏អត្រាអតិផរណាឆ្នាំ ២០១៤ នឹងរំពឹងថាមានកម្រិតទាបជាង ៥% ដោយសារមានកំណើនផលិតកម្ម និងគោលនយោបាយរក្សាស្ថេរភាពថ្លៃ។

២) ក្នុង៦ខែដើមឆ្នាំ២០១៤ វិស័យសំណង់មានការថយចុះបន្តិច ដោយសារការថយចុះនៃសំណង់ពាណិជ្ជកម្មធំៗ ក៏ប៉ុន្តែចំនួនគម្រោងសាងសង់ដែលបានស្នើសុំក្នុងឆមាសទី១ ឆ្នាំ២០១៤ មានការកើនឡើងបើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៣ ជាពិសេសគម្រោងសំណង់លំនៅឋាន និងឧស្សាហកម្ម។

៣) ចំនួនអ្នកទេសចរតាមផ្លូវគោក និងទឹកមានការថយចុះ ជាពិសេសអ្នកទេសចរ វៀតណាម និងចិន។

*សេចក្តីសន្និដ្ឋានៈ*

ទោះជាស្ថិតក្នុងស្ថានភាពនយោបាយមិនសូវអំណោយផល ក៏សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជានាឆមាសទី១ ឆ្នាំ២០១៤ សម្រេចបានលទ្ធផលជាវិជ្ជមានរួមមាន ការផ្តល់ឥណទាន ផលិតកម្មនិងការនាំចេញវាយនភណ្ឌនិងស្បែកជើង វិនិយោគបរទេស និងទេសចរណ៍ បានបង្ហាញអំពីកំណើនធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៣។

យ៉ាងណាមិញ សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដូចជា ចំណាយថវិកាជាតិមានការយឺតយ៉ាវ អត្រាការប្រាក់កម្ចីនៅតែខ្ពស់ មានការនាំចូលច្រើននូវបន្លែនិងផ្លែឈើ ការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើងមានកំណើនទាប និងមិនមានកំណើនការនាំចេញអង្ករ ។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម សុខហេង ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៧/១៤ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសជាផ្លូវការដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ និងពិធីអបអរសាទរខួបលើកទី៥នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធជនពិការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២ | ០៣/០៧/១៤ ម៉ោង ១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៣/០៧/១៤ ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ÷<br>១-សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។<br>២-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/០៧/១៤ ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាស្តីពីការពង្រីកស្ថានីយ៍អ្នកដំណើរនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៨/០៧/១៤ ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យ នៅជាប់របងជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១០/០៧/១៤ ម៉ោង ១៨:០០នាទី | ចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋានឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ៧ | ១១/០៧/១៤ ម៉ោង ០៦:១០នាទី | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិ ព្រះករុណា "ព្រះបរមរតនកោដ្ឋ" នៅមុខព្រះបរម រាជវាំង។ |
| ៨ | ១១/០៧/១៤ ម៉ោង ១៧:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក Pierre COPPEY អគ្គនាយកប្រតិភូក្រុមហ៊ុន VINCI នៅរាជធានី ភ្នំពេញ។ |
| ៩ | ១៤/០៧/១៤ ម៉ោង ១៨:០០នាទី | ចូលរួមអមដំណើរឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីបុណ្យជាតិនៃសាធារណរដ្ឋបារាំង នៅស្ថានទូតបារាំង។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៤ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១០ | **១៥/០៧/១៤ ម៉ោង ០៩:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយលោក **ទិត្យ សុផា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **១៥/០៧/១៤ ម៉ោង ១០:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **១៦/០៧/១៤ ម៉ោង ០៩:៣០នាទី** | ជួបប្រជុំពិភាក្សាការងារដែលពាក់ព័ន្ធទៅនឹងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាមួយ ឯកឧត្តម **ផែង សុខជាទោ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **១៦/០៧/១៤ ម៉ោង ១១:០០នាទី** | ជួបប្រជុំពិភាក្សាការងារ ជាមួយឯកឧត្តម **ម៉ម សុផាណា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **១៨/០៧/១៤ ម៉ោង ០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម÷<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌។<br>៤-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិ លើ៖<br>៤.១-ពិធីសារណាហ្គូយ៉ាស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ ការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌នៃអនុសញ្ញាសហប្រជាជាតិ ស្តីពីជីវៈចម្រុះ។<br>៤.២-កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការវប្បធម៌ រវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៥ | **២១/០៧/១៤ ម៉ោង ០៨:៣០នាទី** | ចូលរួមអមដំណើរឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីជូនភ្លើងបូជាសពឯកឧត្តម **ប្រាក់ សុខ** នៅវត្តបុទុមវត្តី។ |
| ១៦ | **២២/០៧/១៤ ម៉ោង ១៥:៣០នាទី** | ចូលរួមស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន IATA ស្តីពីប្លង់មេព្រលានយន្តហោះនៅព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៧ | ២៣/០៧/១៤<br>ម៉ោង ០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារអំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim អ្នកគ្រប់គ្រងក្រុមហ៊ុន ម៉ាន់ស៊ូដេញ្ជូតិច នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | ២៤/០៧/១៤<br>ម៉ោង ១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ២៩/០៧/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រសម្បទា ខាងវិជ្ជាជីវៈមេធាវីជំនាន់ទី១០-១១ និងទី១២ និងបើកវគ្គបណ្តុះបណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលាភូមិន្ទរដ្ឋបាល។ |
| ២០ | ២៩/០៧/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ÷<br>១-សេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | ៣០/០៧/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ÷<br>១-សេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | ៣១/០៧/១៤<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ស្ពានអាកាសស្ទឹងមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ។ |
| ២៣ | ៣១/០៧/១៤<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទមហោស្រពចម្រៀងខ្មែរជាសាកល ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

# សិក្ខាសាលាស្តីពី
# ការបញ្ជៀបការយល់ដឹងជាសាធារណៈចំពោះ ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការជួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ADB បានរៀបចំសិក្ខាសាលស្តីពីការបញ្ចៀបការយល់ដឹងជាសាធារណៈចំពោះការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA)ចំនួន៣លើក ទី១-សាកលវិទ្យាមេគង្គកម្ពុជា នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ទី២-អគ្គលេខាធិការដ្ឋានរដ្ឋសភា នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ និងទី៣-ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៤ ក្រោមអធិបតីភាពឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA និងថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នទាំងបីនេះ។



ឯកឧត្តម **យឹម ណុលសន** នាយកគម្រោង RIA

ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA បានបញ្ជាក់នៅក្នុងសិក្ខាសាលាទាំងបីនេះថា គម្រោងវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ដែលទទួលបានជំនួយពី ADB បានចាប់ផ្តើមដំណើរការនៅឆ្នាំ ២០០៨ គ្រាដែលពិភពលោកកំពុងជួបវិបត្តិសេដ្ឋ កិច្ច។

ឯកឧត្តម **យឹម ណុលសន** បានបន្តថា គំនិតផ្តួចផ្តើមកសាងគម្រោងនេះ ធ្វើឡើងដើម្បីឆ្លើយតប និងធានាបាននូវការប្រព្រឹត្តទៅនៃធុរកិច្ចរបស់កម្ពុជា។

ឯកឧត្តម បន្តទៀតថា ដើម្បីឲ្យកម្ពុជាអាចប្រកួតប្រជែងនូវសេដ្ឋកិច្ច ក៏ដូចជាបញ្ហានានា ជាមួយប្រទេសក្នុងតំបន់ និងពិភពលោកបានខ្លាំងពូកែ កម្ពុជាត្រូវតែមានលិខិតបទដ្ឋានគតិយុត្តដែលរឹងមាំ និងល្អប្រសើរ ហើយដើម្បីធ្វើឲ្យការកសាងលិខិតបទដ្ឋានគតិយុត្តនោះបានល្អប្រសើរ គឺត្រូវតែមានការគិតគូ និងវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ។

សូមបញ្ជាក់ថា ដោយមើលឃើញពីភាពល្អប្រសើរនៃគម្រោង RIA ក្រសួងចំនួន ៧ ត្រូវបានដាក់ឲ្យអនុវត្តគម្រោងមួយនេះ រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ។

ក្រោយដាក់ឲ្យអនុវត្តគម្រោង មន្ត្រីនៃក្រសួងទាំង៧ ត្រូវបានយកទៅបណ្តុះបណ្តាល ដោយអ្នកជំនាញអន្តរជាតិមកពីប្រទេសអូស្ត្រាលី ព្រមទាំងបានបញ្ជូនទៅសិក្សារកបទពិសោធន៍នៅបណ្តាប្រទេសជឿនលឿនជាច្រើន ដូចជា អូស្ត្រាលី ចក្រភពអង់គ្លេស និងប្រទេសវៀតណាមជាដើម ។

គម្រោង RIA ក្រោយពីការដាក់អនុវត្តរយៈពេលជាច្រើនឆ្នាំមកនេះ ទទួលបានការកោតសរសើរ និងវាយតម្លៃខ្ពស់ពីធនាគារអភិវឌ្ឍន៍អាស៊ីខាងគម្រោង សម្រេចបានលទ្ធផលល្អប្រសើរគួរជាទីមោទនភាព។

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in